# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ប្រកាសព័ត៌មាន
## ស្ដីពី
## ដំណើរការនៃការធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី គ.ជ.ប ទៅក្នុងក្របខណ្ឌ និងនីតិវិធីនៃការតែងតាំងមន្ត្រីរាជការ

### សេចក្ដីផ្ដើម

តាំងតែពីកើត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០១៥ គ.ជ.ប មានអាយុកាល១៧ ឆ្នាំហើយ ។ ក្នុងរយៈពេលនេះ គ.ជ.ប បានរៀបចំបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន១១លើករួចមកហើយ ។ រីឯមន្ត្រី គ.ជ.ប គ្រប់ជាន់ថ្នាក់សុទ្ធតែជាមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ។ ការបំពេញភារកិច្ចរបស់មន្ត្រីទាំងនោះ ខ្លះមានរយៈពេលវែង និងខ្លះទៀតមានរយៈពេលខ្លី ។ ជារួមមន្ត្រីស្ថិតនៅក្នុងប្រព័ន្ធអាជីពនេះតែងតែមានអារម្មណ៍មិនសូវនឹងន់ ដោយការងារមិនមានស្ថេរភាព ពីព្រោះពេលចប់កិច្ចសន្យា សាមីជនត្រូវស្វះស្វែងរកការងារធ្វើនៅកន្លែងផ្សេងៗទៀត មិនដូចជាមន្ត្រីរាជការស្ថិតនៅក្នុងប្រព័ន្ធវិជ្ជាជីវៈក្របខណ្ឌឡើយ ។

ដើម្បីបំបាត់កង្វល់អំពីការបាត់បង់ការងារ និងលើកទឹកចិត្តដល់មន្ត្រី គ.ជ.ប ដែលបានខិតខំបម្រើការងារជាច្រើនឆ្នាំកន្លងមក ទើបរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអាណត្តិទី៥ បានអនុម័តច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ហើយថែមទាំងបានបញ្ញត្តិរក្សាទុកមន្ត្រីបន្តនិរន្តរភាពការងារបោះឆ្នោតឲ្យទៅជាមន្ត្រីមានក្របខណ្ឌ ។

### I អំពីដំណើរការនៃការធ្វើសមាហរណកម្ម

ផ្អែកតាមជំពូកទី៣ ផ្នែកទី៣ មាត្រា៥៥ វាក្យខណ្ឌទី៤ នៃច្បាប់អង្គការខាងលើបានចែងថា " មន្ត្រីបុគ្គលិក នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលេខាធិការដ្ឋានគណៈកម្ម-ការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) គឺជាមន្ត្រី បុគ្គលិកស្ថិតក្នុងក្របខណ្ឌ នៃលក្ខន្តិកៈដោយឡែកមួយដែលកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីមានយោបល់ឯកភាពពីក្រសួងមុខងារសាធារណៈ " ។

អនុវត្តតាមមាត្រា៥៥ នៃច្បាប់អង្គការនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីមានយោបល់ឯកភាពពីក្រសួងមុខងារសាធារណៈ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានចេញ

ព្រះរាជក្រឹត្យ លេខនស/រកត/០៦១៥/៦៤៨ ចុះថ្ងៃ ទី១៧ មិថុនា ឆ្នាំ២០១៥ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយកំណត់ឲ្យមន្ត្រី គ.ជ.ប មាន ៣ក្របខណ្ឌ គឺក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់, ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម និងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ។

+ចំពោះក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ត្រូវបានបែងចែកជាបីឋានន្តរសក្តិ :

-ឧត្តមមន្ត្រីមាន ០៦ថ្នាក់

-វរមន្ត្រីមាន ០៤ថ្នាក់

-អនុមន្ត្រីមាន០៤ថ្នាក់ ។

+ចំពោះក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យមត្រូវបានបែងចែកជាបីឋានន្តរសក្តិ :

-នាយក្រមការមាន ០៦ថ្នាក់

-ក្រមការដើមខ្សែមាន ០៤ថ្នាក់

-ក្រមការមាន ០៤ថ្នាក់ ។

+ចំពោះក្របខណ្ឌមន្ត្រីបោះឆ្នោតបឋមមានដប់ថ្នាក់ ។

ដើម្បីធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រីបុគ្គលិកទៅក្នុងក្របខណ្ឌ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានកសាងសេចក្តីសម្រេចលេខ១០៦ /១៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប បន្ទាប់ពីបានពិគ្រោះជាផ្លូវការជាមួយក្រសួងមុខងារសាធារណៈ ស្របតាមស្មារតីនៃច្បាប់អង្គការគ្រង់ជំពូកទី៥ មាត្រា៦៤ វាក្យខណ្ឌទី៣ដែលបានចែងថា "មន្ត្រីបុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌនៃលក្ខន្តិកៈដោយឡែក ដូចមានចែងក្នុងវាក្យខណ្ឌទី៤នៃ មាត្រា៥៥នៃច្បាប់នេះ" ។

ទោះបីជាមានព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្មក៏ដោយ គ.ជ.ប នៅតែពុំទាន់មានលទ្ធភាពធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រីទៅក្នុងក្របខណ្ឌបាននៅឡើយ ដោយចាំបាច់ត្រូវចេញសេចក្តីណែនាំលេខ២៧៣/១៥ គ.ជ.ប ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការអនុវត្តគោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប និងបានបង្កើតគណៈកម្មការសមាហរណកម្មស្របតាមប្រការ២០នៃ សេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្ម ដែលបានចែងថា : គ.ជ.ប ត្រូវបង្កើតគណៈកម្មការសមារណកម្ម ដើម្បីរៀបចំធ្វើសមាហរណកម្មមន្ត្រី ដែលកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប ទៅតាមគោលការណ៍ខាងលើ ។ ការធ្វើសមាហរណកម្មត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការសមាហរណកម្ម ។ មានន័យថា គណៈកម្មការសមាហរណកម្មគ្រាន់តែជាជំនួយការឲ្យ គ.ជ.ប តែប៉ុណ្ណោះការសម្រេចចុងក្រោយគឺអាស្រ័យលើ គ.ជ.ប ។ ដើម្បីសម្រួលដល់ការងារសមាហរណកម្ម គ.ជ.ប ក៏បានបង្កើតក្រុមជំនួយការសម្រាប់ជួយការងារដល់គណៈកម្មការខាងលើ ដែលមានប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាលជាប្រធាន ។

ក្រុមការងារបានដំណើរការធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី ទៅក្នុងក្របខណ្ឌតាមគោលការណ៍ ០៣យ៉ាងគឺ :

- ការធ្វើសមាហរណកម្មតាមមុខតំណែង
- ការធ្វើសមាហរណកម្មតាមអតីតភាពការងារ
- និងការធ្វើសមាហរណកម្មតាមកម្រិតសញ្ញាបត្រ ។

**១ ការធ្វើសមាហរណកម្មតាមមុខតំណែង**

**១.១ ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់**

ផ្អែកតាមសេចក្ដីសម្រេចស្ដីពីគោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌមន្ត្រីពជាការនៃ គ.ជ.ប ខាងលើនេះ ត្រង់ជំពូកទី២ ប្រការ៤ បានចែងថា « មន្ត្រីកំពុងបម្រើការងារ នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុង**ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់** "ប្រភេទក្របខណ្ឌ ក" គឺជាមន្ត្រីទាំងឡាយណាដែលកំពុងកាន់មុខតំណែងពិតប្រាកដ នៅក្នុងអង្គការលេខនៃ រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប មាន ៖

**ក-ឋានន្តរសក្តិឧត្តមមន្ត្រី**

-អគ្គលេខាធិការ

-អគ្គលេខាធិការរង

-និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ ។

**ខ-ឋានន្តរសក្តិវរមន្ត្រី**

-ប្រធាននាយកដ្ឋាន

-និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ ។

**គ-ឋានន្តរសក្តិអនុមន្ត្រី**

-អនុប្រធាននាយកដ្ឋាន

-ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប )

-និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ ។ »

**១.២ ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម**

ផ្អែកតាមសេចក្ដីសម្រេចស្ដីពីគោលការណ៍សមាហរណកម្មខាងលើនេះ ត្រង់ជំពូកទី២ ប្រការ៧ បានចែងថា « មន្ត្រីកំពុងបម្រើការងារ នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុង**ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម** "ប្រភេទក្របខណ្ឌ ខ" គឺជាមន្ត្រីទាំងឡាយណា ដែលកំពុងកាន់មុខតំណែងពិតប្រាកដ នៅក្នុងអង្គការលេខនៃ រចនាសម្ព័ន្ធរបស់អគ្គលេខា-ធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប មាន ៖

**ក-ឋានន្តរសក្តិនាយក្រមការ**

-ប្រធានការិយាល័យ

-អនុប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប )

-និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ ។

**ខ-ឋានន្តរសក្តិក្រមការដើមខ្សែ**

-អនុប្រធានការិយាល័យ

-និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ ។

**គ- ឋានន្តរសក្តិក្រមការ**

-មន្ត្រីជំនាញ

-និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ ។ »

ចំពោះការធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី បុគ្គលិកនៃ គ.ជ.ប និង លធ.ខប ចូលទៅក្នុងក្របខណ្ឌគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាលទ្ធផលមានដូចខាងក្រោម ៖

**ក. ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់**

**ក_១ ឋានន្តរសក្តិឧត្តមមន្ត្រី**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ**ឧត្តមមន្ត្រី**មានចំនួន១៩ រូប រួមមានអគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើ ដែលក្នុងនោះ គ.ជ.ប បានសម្រេចលើកទឹកចិត្តដល់អតីតប្រធាននាយកដ្ឋាន និងមន្ត្រីដែលមានឋានៈស្មើចំនួន០៧ រូបផងដែរ ។

**ក_២ ឋានន្តរសក្តិវរមន្ត្រី**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ**វរមន្ត្រី**មានចំនួន ៣០ រូប រួមមានប្រធាននាយកដ្ឋាន និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើ ។

**ក_៣ ឋានន្តរសក្តិអនុមន្ត្រី**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ**អនុមន្ត្រី**មានចំនួន៤២ រូប រួមមានអនុប្រធាននាយកដ្ឋាន ប្រធានលធ.ខប និងមន្ត្រីដែលមានមុខតំណែងឯទៀត ដែលមានឋានៈស្មើ។

**ខ. ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម**

**ខ_១ ឋានន្តរសក្តិនាយក្រមការ**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ**នាយក្រមការ**មានចំនួន១៧ រូប រួមមានប្រធានការិយាល័យ អនុប្រធានលធ.ខប និងមន្ត្រីដែលមានមុខតំណែងឯទៀតដែលមានឋានៈស្មើ ។

**ខ_២ ឋានន្តរសក្តិក្រមការដើមខ្សែ**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ**ក្រមការដើមខ្សែ**មានចំនួន០៧ រូប រួមមានអនុប្រធានការិយាល័យ និងមន្ត្រីដែលមានមុខតំណែងឯទៀតដែលមានឋានៈស្មើ ។

**ខ_៣ ឋានន្តរសក្តិក្រមការ**

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ**ក្រមការ**មានចំនួន១៤ រូប ជាមន្ត្រីជំនាញ ។

**២ ការធ្វើសមាហរណកម្មតាមអតីតភាពការងារ**

ផ្អែកតាមសេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្មខាងលើនេះ ក្នុងជំពូកទី៣ ត្រង់ប្រការ១០ បានចែងថា « មន្ត្រីកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និងលធ.ខប ក្រៅពីមន្ត្រីដែលបានធ្វើសមាហរណកម្មទៅតាមមុខតំណែងខាងលើ ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម "ប្រភេទក្របខណ្ឌ គ" ដោយគិតតាមអតីតភាពការងារ ។ »

ចំពោះការធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី បុគ្គលិកនៃ គ.ជ.ប និង លធ.ខប ចូលទៅក្នុងក្របខណ្ឌ ជាលទ្ធផលមានដូចខាងក្រោម ៖

**ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម**

ការងារធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី បុគ្គលិកចូលទៅក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋមនេះ មានចំនួន៩១ រូប ដែលជាលេខាធិការ ការីកុំព្យូទ័រ និងការីការងាររដ្ឋបាល ។

**៣ ការធ្វើសមាហរណកម្មតាមសញ្ញាបត្រ**

ផ្អែកតាមសេចក្តីសម្រេចស្តីពីគោលការណ៍សមាហរណកម្មខាងលើនេះ ក្នុងជំពូកទី៤ ត្រង់ប្រការ១៣ បានចែងថា « មន្ត្រីកំពុងបម្រើការងារ នៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលកំពុងកាន់មុខតំណែងដូចមានចែងក្នុងប្រការ៧ ហើយមានបរិញ្ញាបត្រ ឬមានសញ្ញាបត្រសមមូលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ។

មន្ត្រីដែលកំពុងបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ដែលមានសញ្ញាបត្រខ្ពស់ជាងមុខតំណែងរបស់ខ្លួន នៅពេលធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌថ្មី ត្រូវគិតទៅតាមកម្រិតសញ្ញាបត្រ ។

សមាជិកខុទ្ទកាល័យ និងសមាជិកក្រុមជំនួយការងាររបស់ថ្នាក់ដឹកនាំ គ.ជ.ប ត្រូវបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខណ្ឌតាមមុខតំណែងដែលមានឋានៈស្មើ ឬតាមកម្រិតសញ្ញាបត្រ សម្រាប់ការធ្វើសមាហរណកម្មលើកដំបូងនេះតែប៉ុណ្ណោះ ។ »

អនុវត្តតាមសេចក្តីណែនាំស្តីពីការអនុវត្តគោលការណ៍សមាហរណកម្មមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប ទៅក្នុងក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប ដែលបានលើកឡើងខាងលើ ត្រង់ចំនុចទី១ ចំនុចគ នោះបានចែងថា : មន្ត្រីចាប់ពីថ្នាក់ប្រធានការិយាល័យ ឬមានឋានៈស្មើនឹងមុខតំណែងនេះចុះក្រោម មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រសមមូល ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិអនុមន្ត្រីថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ។

មន្ត្រីចាប់ពីថ្នាក់លេខាធិការ ឬការីកុំព្យូទ័រចុះក្រោម មានសញ្ញាបត្រទុតិយភូមិបូកវគ្គបណ្តុះបណ្តាលរយៈពេល២(ពីរ) ឆ្នាំ (បរិញ្ញាបត្ររង) ត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិក្រមការ ថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ។

ចំពោះការធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី បុគ្គលិកនៃ គ.ជ.ប និង លធ.ខប ចូលទៅក្នុងក្របខណ្ឌតាមកម្រិតសញ្ញាបត្រ ជាលទ្ធផលមានដូចខាងក្រោម ៖

មន្ត្រីដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិអនុមន្ត្រីមានចំនួន ១០៥ រូប រួមមាន អ្នកដែលមានបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន២៣ រូប អ្នកដែលមានបរិញ្ញាបត្រមានចំនួន៨២រូប និង ឋានន្តរសក្តិក្រមការ ចំពោះអ្នកដែលមានបរិញ្ញាបត្ររងមានចំនួន០៧រូប ។

ដោយពិនិត្យលើសន្ទស្សន៍បៀវត្សរបស់មន្ត្រីដែលមានឋានន្តរសក្តិនាយក្រមការនៃ ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ខ្ពស់ជាងសន្ទស្សន៍បៀវត្សរបស់មន្ត្រីដែលមានឋានន្តរសក្តិអនុមន្ត្រីនៃ ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ គ.ជ.ប បានសម្រេចឲ្យមន្ត្រី ដែលមានមុខតំណែងជាប្រធានការិយាល័យ ហើយមានសញ្ញាបត្របរិញ្ញាបត្រឡើង និងមានអតីតភាពការងារចាប់ពី៥ឆ្នាំ ដល់១០ឆ្នាំ ត្រូវតម្លើង០១ថ្នាក់ បើមានអតីតភាពការងារចាប់ពី១០ឆ្នាំឡើងទៅត្រូវតម្លើង០២ថ្នាក់ ។

សរុបមក គ.ជ.ប បានធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រីទៅក្នុងក្របខណ្ឌមានចំនួន៣៣២ រូប មានដូចតទៅ ៖

-ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់មានចំនួន១៩៦ រូប រួមមានឋានន្តរសក្តិឧត្តមមន្ត្រីចំនួន១៩ រូប ឋានន្តរសក្តិវរមន្ត្រីចំនួន៣០ រូប ឋានន្តរសក្តិអនុមន្ត្រីចំនួន១៤៧ រូប(តាមមុខតំណែងចំនួន៩២ រូប និង តាមសញ្ញាបត្រចំនួន១០៥ រូប)

-ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យមមានចំនួន៤៥ រូប រួមមានឋានន្តរសក្តិនាយក្រមការចំនួន១៧ រូប ឋានន្តរសក្តិក្រមការដើមខ្សែចំនួន០៧ រូប និងឋានន្តរសក្តិក្រមការចំនួន២១ រូប (តាមមុខតំណែងចំនួន ១៤ រូប និងតាមសញ្ញាបត្រចំនួន០៧រូប)

-ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋមមានចំនួន៩១ រូប ។

## II អំពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការ

ផ្អែកតាមអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប បានកំណត់រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មាន០៨នាយកដ្ឋាន និងមានលេខាធិការដ្ឋាននៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប ០១ ផង ។ ផ្អែកតាម សេចក្តីសម្រេចលេខ១៣៤/១៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំរចនាសម្ព័ន្ធ របស់នាយកដ្ឋាន និងតួនាទី ភារកិច្ចរបស់ការិយាល័យ និងលេខាធិការដ្ឋានគណកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត បានកំណត់អំពីចំនួនការិយាល័យនៅតាមនាយកដ្ឋាននីមួយៗ លេខាធិការដ្ឋាននៃ អគ្គលេខាធិការដ្ឋាន និង លធ.ខប ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំ តែងតាំងមន្ត្រីចូលក្នុងរចនាសម្ព័ន្ធខាងលើ ។

- មុខតំណែងអគ្គលេខាធិការ និងអគ្គលេខាធិការរង គឺមន្ត្រីទាំងឡាយណា ដែលមានឋានន្តរសក្តិ ឧត្តមមន្ត្រីនៃ ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់
- មុខតំណែងប្រធាននាយកដ្ឋាន និងប្រធានលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គឺមន្ត្រីទាំង ឡាយណាដែលមានឋានន្តរសក្តិវរមន្ត្រីនៃ ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់
- មុខតំណែងអនុប្រធាននាយកដ្ឋាន ប្រធានលធ.ខប និងអនុប្រធានលេខាធិការដ្ឋាននៃអគ្គលេខា-ធិការដ្ឋាន គឺមន្ត្រីទាំងឡាយណាដែលមានឋានន្តរសក្តិអនុមន្ត្រីនៃ ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់
- មុខតំណែងប្រធានការិយាល័យ អនុប្រធានលធ.ខប និងប្រធានក្រុមការងារនៃលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គឺមន្ត្រីទាំងឡាយណា ដែលមានឋានន្តរសក្តិនាយក្រមការ នៃក្របខណ្ឌ មន្ត្រីបោះឆ្នោតមធ្យម
- មុខតំណែងអនុប្រធានការិយាល័យ គឺមន្ត្រីទាំងឡាយណា ដែលមានឋានន្តរសក្តិក្រមការដើមខ្សែ នៃក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ។

ទោះបីមានការកំណត់ឋានន្តរសក្តិទៅតាមមុខតំណែងនីមួយៗក៏ពិតមែន ប៉ុន្តែជាក់ស្តែងមានមន្ត្រី ដែលមានឋានន្តរសក្តិឧត្តមមន្ត្រីកាន់មុខតំណែងជាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធាន ការិយាល័យ និង មន្ត្រីមានឋានន្តរសក្តិអនុមន្ត្រីនៃ ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ កាន់មុខតំណែងជា ប្រធានការិយាល័យ និងអនុប្រធានការិយាល័យផងដែរ ។

ដំណើរការធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រី គ.ជ.ប ទៅក្នុងក្របខណ្ឌនេះ គ.ជ.ប បានខិតខំធ្វើ ការងារដោយចំណាយអស់រយៈពេល០៩ ខែ ទើបបានបញ្ចប់ជាស្ថាពរ ដោយគិតចាប់ពីខែឧសភា ឆ្នាំ២០១៥ រហូតដល់ខែមករា ឆ្នាំ២០១៦ ។

**រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦**